**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**

៣៣៣*៧៧

**សភាព្រហ្មទណ្ឌ**

សំណុំរឿងលេខៈ ៣១៦

ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

**សាលដីកាលេខៈ ៤៦៩(ខ)**

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

17-10-22

ស៊ ២០៥

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះ ដូចខាងក្រោម ៖

១.លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

៣.លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជម្រះ**

លើបណ្ដឹងឧទ្ធរណ៍លេខ ៣៥៧៣, ៣៥៧៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]បូរី និងជនជាប់ចោទឈ្មោះ [redacted]ដែរ ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ជ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] បូរី ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរ [illegible] មានទីលំនៅបច្ចុប្បន្នភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរបីជាន់ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted]ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៦នាក់ (ទោសពីមុនគ្មាន) (ក្នុងឃុំ) (ជាអ្នកប្ដឹងឧទ្ធរណ៍)

មានលោកស្រី [redacted]រដ្ឋា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៣៦ ព្រទ.III"ឃ"/២១ ចុះថ្ងៃទី២៥.០៥.២០២១។



Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] ដែរ ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ មានទីលំនៅបច្ចុប្បន្នភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរបីជាន់ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted]។ ម្តាយឈ្មោះ [redacted] នៅលើវ (ទោសពីមុនគ្មាន)។ (ឃុំ) (ជាអ្នកប្តឹងឧទ្ធរណ៍)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៣៧ ព្រទ.III·ឃ·/២១ ចុះថ្ងៃទី២៥.០៥.២០២១។

**ជាប់ចោទពីបទៈ** ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរបីជាន់ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**អំពីអង្គហេតុ៖**

-កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង២ និង ៤០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលអូរបីជាន់បានល្បាតក្នុងព្រៃឫស្សី ស្ថិតក្នុងភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានប្រទះឃើញពលករលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ចំនួន ១៩នាក់។ បន្ទាប់មកសមត្ថកិច្ចបាននាំពលករទាំងអស់មកធ្វើការសាកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលអូរបីជាន់ ទើបបានដឹងថាឈ្មោះ [redacted] ដែរ និងឈ្មោះ [redacted] បូរី ជាមេខ្យល់នាំពលករទាំងនេះឆ្លងដែនទៅប្រទេសថៃខុសច្បាប់។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ជ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចៈ

១-ផ្តន្ទាទោសៈ

ក-ឈ្មោះ [redacted] បូរី ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ

ខ-ឈ្មោះ [redacted] ដែរ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ

ពីបទៈ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣៥៧៣, ៣៥៧៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] បូរី និងជនជាប់ចោទឈ្មោះ [redacted] ដែរ ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ជ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ប្តឹងគ្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ របាយការណ៍របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍។

-ជនជាប់ចោទឈ្មោះ [redacted] ដែរ បានឆ្លើយថាៈ ខ្ញុំបាទអាចនិយាយខ្លួនឯងបានដោយមិនបាច់មានមេធាវី ការដែលខ្ញុំប្តឹងមកនេះគឺសាលាដំបូងបានដាក់ទោសខ្ញុំច្រើនពេក ចំពោះអង្គហេតុខ្ញុំទទួលស្គាល់ទាំងអស់ តែចង់សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្ញុំខ្លះ។

-ជនជាប់ចោទឈ្មោះ [redacted] បូរី បានឆ្លើយថាៈ ខ្ញុំមិនសុខចិត្តដោយសារខ្ញុំមិនបានស្គាល់មុខរបស់គេទេ ហើយចម្លើយចេញពីរដ្ឋបាលគឺខុសនឹងចម្លើយដែលខ្ញុំបានឆ្លើយ។ ដោយពេលនឹងគាត់សួរខ្ញុំថាថ្ងៃហ្នឹងទៅនៅណា ខ្ញុំក៏បានឆ្លើយថានៅច្រកឡុង ដល់ថ្ងៃម៉ោង ១២ ខ្ញុំអត់មានម្ហូបហូបបាយ ខ្ញុំក៏បាននាំប្អូនរបស់ខ្ញុំទៅ

ដីកចៀស និងកម្ទេចផ្សេងៗមកហូប។ ហើយខ្ញុំមិនបានដឹកពលករទេ ហើយចម្លើយរបស់ខ្ញុំតាំងពីរដ្ឋបាល ក៏មិនដែលបានឆ្លើយដែរ ហើយចម្លើយនៅសាលាដំបូងខ្ញុំបានឆ្លើយថាមិនបានប្រព្រឹត្តទេ។

-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឃើញថាជនជាប់ចោទម្នាក់បានសារភាព និងជនជាប់ចោទម្នាក់ទៀតមិនបានសារភាព ដោយយោងតាមចម្លើយរបស់ជនជាប់ចោទម្នាក់ដែលបានរៀបរាប់ យើងតំណាងអយ្យការស្នើសុំឱ្យប្រធានក្រុមប្រឹក្សា និងចៅក្រមប្រឹក្សាពិនិត្យ និងសម្រេចទៅតាមច្បាប់។

-លោកស្រី [redacted] រដ្ឋា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បូរី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសាកសួរដេញដោល និងឯកសារដែលមាននៅក្នុងសំណុំរឿងឃើញថា កូនក្តីនាងខ្ញុំគាត់មានការប្រែប្រួលចម្លើយ ហើយក៏ជាកំហុសរបស់គាត់ដែរ ដូចលោកចៅក្រមប្រឹក្សាគាត់បានដេញដោលនៅពេលនេះ ថាពេលនោះគាត់មិនបានយកភស្តុតាងដោះបន្ទុក ដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់គាត់នៅសាលាដំបូងទេ ដូចនេះនាងខ្ញុំជាមេធាវីការពារសិទ្ធិស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សា ក៏ដូចជាចៅក្រមប្រឹក្សាមេត្តាពិចារណាលើអង្គហេតុនេះ និងសុំឱ្យផ្តន្ទាទោសកូនក្តីនាងខ្ញុំជាកម្រិតអប្បបរមានៃទោស ហើយសាលាដំបូងខេត្តបន្ទាយមានជ័យក៏បានកែប្រែបទចោទពីបទៈ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផងដែរ។

-ជនជាប់ចោទឈ្មោះ [redacted] ដែរ បានធ្វើការសំណូមពរចុងក្រោយថាៈ សុំឱ្យលោកតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្ញុំផង ដើម្បីទៅថែឪពុកចាស់នៅផ្ទះ។

-ជនជាប់ចោទឈ្មោះ [redacted] បូរី បានធ្វើការសំណូមពរចុងក្រោយថាៈ សុំឱ្យលោកតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្ញុំផង ដើម្បីមើលប្រពន្ធកូនខ្ញី និងថែម្តាយចាស់នៅផ្ទះ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

១-យល់ឃើញថា បណ្តឹងឧទ្ធរណ៍លេខ ៣៩៧៣, ៣៩៧៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] បូរី និងជនជាប់ចោទឈ្មោះ [redacted] ដែរ ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ជ" ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៧៣, ៣៧៥, ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមការលើកឡើងជនជាប់ចោទឈ្មោះ [redacted] ដែរ នាពេលសវនាការថាៈ ការដែលខ្ញុំប្តឹងមកនេះគឺសាលាដំបូងបានដាក់ទោសខ្ញុំច្រើនពេក។ ចំពោះអង្គហេតុខ្ញុំទទួលស្គាល់ទាំងអស់ គ្រាន់តែចង់សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនខ្លះ។ ចំណែកឯ ជនជាប់ចោទឈ្មោះ [redacted] បូរី បានឆ្លើយបដិសេធថា ខ្ញុំមិនសុខចិត្តដោយសារខ្ញុំមិនបានរកស៊ីមុខរបរនឹងទេ ហើយចម្លើយចេញពីរដ្ឋបាលគឺខ្ញុំមិនបានឆ្លើយដូចនោះទេ ខ្ញុំបានឆ្លើយ។ ដោយពេលនឹងគាត់សួរខ្ញុំថាថ្ងៃកើតហេតុនៅណា ខ្ញុំក៏បានឆ្លើយថានៅច្រកជ្រៀង ដីស្រែថ្ងៃម៉ោង១២



Scanned with CamScanner

ខ្ញុំអត់មានម្ហូបហូបបាយខ្ញុំក៏បាននាំប្អូនរបស់ខ្ញុំទៅដឹកជៀស និងរកម្ហូបផ្សេងៗមកហូប។ ហើយខ្ញុំមិនបានដឹកពលករទេ ហើយចម្លើយរបស់ខ្ញុំតាំងពីរដ្ឋបាលក៏មិនដែលបានឆ្លើយដែរ ហើយចម្លើយនៅសាលាដំបូងខ្ញុំបានឆ្លើយថាមិនបានប្រព្រឹត្តទេ។ ក៏ប៉ុន្តែ ចម្លើយនេះមានភាពផ្ទុយគ្នាទៅនឹងសេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទថា ឆ្លងតាមការសាកសួរដេញដោល និងឯកសារដែលមាននៅក្នុងសំណុំរឿងឃើញថា កូនក្តីនាងខ្ញុំគាត់មានការប្រែប្រួលចម្លើយ ហើយក៏ជាកំហុសរបស់គាត់ដែរ។ ដូចលោកចៅក្រមគាត់បានដេញដោលនៅពេលនេះ ថាពេលនោះគាត់មិនបានយកភស្តុតាងដោះបន្ទុកដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់គាត់នៅសាលាដំបូងទេ ដូចនេះនាងខ្ញុំជាមេធាវីការពារសិទ្ធិស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សា ក៏ដូចជាចៅក្រមប្រឹក្សាមេត្តាពិចារណាលើអង្គហេតុនេះ និងសុំឱ្យផ្តន្ទាទោសកូនក្តីនាងខ្ញុំជាកម្រិតអប្បបរមានៃទោស ហើយសាលាដំបូងខេត្តបន្ទាយមានជ័យក៏បានកែប្រែបទចោទជាបទ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផងដែរ។ ការលើកឡើងរបស់ជនជាប់ចោទឈ្មោះ [redacted] ដែរ ក្រុមប្រឹក្សាជំនុំជម្រះអាចពិចារណាបាន ព្រោះជនជាប់ចោទបានទទួលស្គាល់កំហុសហើយ ហើយគ្រាន់តែស្នើសុំបន្ធូរបន្ថយទោសខ្លះប៉ុណ្ណោះ។ ចំនែកការលើកឡើងរបស់ជនជាប់ចោទឈ្មោះ [redacted]បូរី ខាងលើនេះ ក្រុមប្រឹក្សាជំនុំជម្រះមិនអាចពិចារណាបានទេ ព្រោះជាចម្លើយដោះសារប៉ុណ្ណោះ រីឯការស្នើសុំរបស់លោកស្រីមេធាវីដើម្បីផ្តល់ស្ថានសម្រាលអប្បបរមាលើជនជាប់ចោទរូបនេះ ក្រុមប្រឹក្សាក៏មិនអាចពិចារណាបានដូចគ្នា ព្រោះជនជាប់ចោទមិនទទួលស្គាល់កំហុសរបស់ខ្លួនទាល់តែសោះ ហើយនៅតែព្យាយាមបដិសេធពីការប្រព្រឹត្តរបស់ខ្លួន។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងថា: ឆ្លងតាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឃើញថាជនជាប់ចោទម្នាក់បានសារភាព និងជនជាប់ចោទម្នាក់ទៀតមិនបានសារភាព ដោយយោងតាមចម្លើយរបស់ជនជាប់ចោទម្នាក់ដែលបានរៀបរាប់ យើងតំណាងមហាអយ្យការស្នើសុំឱ្យប្រធានក្រុមប្រឹក្សា និងចៅក្រមប្រឹក្សាពិនិត្យ និងសម្រេចទៅតាមច្បាប់។ ចំណុចនេះ ក្រុមប្រឹក្សាជំនុំជម្រះអាចពិចារណាបាន ដូចទៅនឹងសម្អាងហេតុខាងលើ។

៤-យល់ឃើញថា ខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ជ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ គប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការតម្កល់ទុកជាបានការ ដោយគ្រាន់តែកែប្រែលើទណ្ឌកម្មរបស់ជនជាប់ចោទឈ្មោះ [redacted] ដែរ ដែលបានទទួលស្គាល់កំហុស និងសុំតុលាការបន្ធូរបន្ថយទោស។

**ហេតុដូច្នេះ**

**សម្រេច**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៥៧៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ ជនជាប់ចោទឈ្មោះ [redacted] ដែរ ទុកជាត្រឹមត្រូវតាមច្បាប់ និងបណ្តឹងឧទ្ធរណ៍លេខ ៣៥៧៣ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]បូរី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយទាស់ទៅនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ជ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល លើកលែងចំណុចស្តីពីការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ដែល ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ត្រូវកែប្រែមកជា ផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ ៦ខែវិញ។

ចំណុចផ្សេងពីនេះ ត្រូវរក្សាទុកជាបានការដដែល។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះនាសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បូរី និង [redacted] ដែរ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] | [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

បាត់ដំបង ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner